ព្រឹត្តិប័ត្រប្រចាំឆមាស


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

The NGO Forum on Cambodia


# ដី ជីវិត


ឆ្នាំទី ៥ ~ លេខ ១២

ខែកក្កដា ~ ខែធ្នូ ឆ្នាំ ២០០៩


បណ្ដាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍

- ការអភិវឌ្ឍន៍ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋក្រីក្រ
- តើដីសម្បទានសេដ្ឋកិច្ចពិតជាផ្ដល់ផលប្រយោជន៍ដល់...
- ក្រុមហ៊ុនពីរប្ដឹងផ្ដល់គ្នាដើម្បីដណ្ដើមយកដីអ្នកភូមិ
- ប្រជាជនក្រីក្ររស់នៅតាមបណ្ដោយផ្លូវជាតិលេខ ៧៨...
- ប្រជាពលរដ្ឋរងគ្រោះព្រោះតវ៉ារឿងទំនាស់ដីធ្លី
- ផ្ទាំងរូបភាពស្ដីពីសិទ្ធិភោគៈស្របច្បាប់ និង ចំរៀង "អាសូរធនធានធម្មជាតិ"











## កម្មវិធីដីធ្លី និងជីវភាព

១- គម្រោងបញ្ហាដីធ្លី

២- គម្រោងតាំងទីលំនៅថ្មី និងសិទ្ធិលំនៅដ្ឋាន

៣- គម្រោងសិទ្ធិជនជាតិដើមភាគតិច

៤- គម្រោងជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ

ព្រឹត្តិប័ត្រប្រចាំឆមាស

ឆ្នាំទី ៥ ~ លេខ ១២

ខែកក្កដា ~ ខែធ្នូ ឆ្នាំ ២០០៩

# ដីជីវិត

## បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍

### អារម្ភកថា

មិត្តអ្នកអានជាទីមេត្រី ព្រឹត្តិប័ត្រដែលកំពុងស្ថិតក្នុងដៃរបស់អស់លោកអ្នកនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការចូលរួមចំណែកពីសមាជិកបណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ បណ្តាញប្រព្រឹត្តិកម្មតាំងទីលំនៅថ្មី បណ្តាញគាំទ្រសិទ្ធិជនជាតិដើមភាគតិច និង បណ្តាញការងារព្រៃឈើ និងចំការឈើដាំ។ ក្នុងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលមានជំហរលើការចែករំលែកព័ត៌មាន ជជែកពិភាក្សាលើការផ្លាស់ប្តូរគោលនយោបាយ និងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា យើងសូមគាំទ្រដល់ការបោះពុម្ពព្រឹត្តិប័ត្រនេះ ដើម្បីចូលរួមចំណែកផ្តល់នូវចំណេះដឹងនានាដែលពាក់ពន្ធ័នឹងការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីអោយមិត្តអ្នកអានបានដឹងថានរណាខ្លះដែលកំពុងនឹងបានក្លាយខ្លួនទៅជាក្រុមជនងាយរងគ្រោះ ដោយសារការបាត់បង់ដីធ្លីនៅកម្ពុជា។

លើសពីនេះទៀត ព្រឹត្តិប័ត្រនេះក៏បានលើកឡើងនូវសំលេង និងផលវិបាកទាំងអស់របស់ប្រជាពលរដ្ឋក្រីក្រទាក់ទងទៅនឹងបញ្ហាដីធ្លី ដើម្បីអោយអ្នកធ្វើគោលនយោបាយទាំងអស់បានដឹងឮ និងងាកមកយកចិត្តទុកដាក់នូវអ្វីដែលជាអាទិភាពសំរាប់ឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ។

យើងខ្ញុំសូមបើកចំហរដើម្បីទទួលនូវមតិយោបល់កែលំអ និងស្វាបនាអោយមានភាពជឿនលឿនទាំងផ្នែកព័ត៌មាន និងចំណេះដឹង យើងខ្ញុំនឹងព្យាយាមបំពេញតាមតំរូវការរបស់អស់លោកអ្នក។

ព្រឹត្តិប័ត្រប្រចាំត្រីមាស
គណៈកម្មការនិពន្ធ និងត្រួតពិនិត្យ

លោក ឈិត សំអាត — នាយកប្រតិបត្តិ
លោក ខាំ ស៊ីខួន — នាយកប្រតិបត្តិរង
លោក ម៉ែន រឿ — ប្រធានកម្មវិធីដីធ្លី និង ជីវភាព
លោក ហិប សុខាន់ណារ៉ូ — អ្នកសម្របសម្រួលមជ្ឈមណ្ឌលព័ត៌មានដីធ្លី
លោកស្រី ទូច សេដ្ឋា — មន្ត្រីគម្រោងដីធ្លី

រចនាអត្ថបទដោយ
លោក ត្នួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ









# ការអភិវឌ្ឍន៍ និង ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋក្រីក្រ

យោងតាមវចនានុក្រមរបស់សម្តេចសង្ឃ ជួន ណាត ពាក្យអភិវឌ្ឍន៍មានន័យថា សេចក្តីចម្រើនក្រៃលែងដែលប្រជាពលរដ្ឋទូទាំងពិភពលោកនេះប្រាថ្នាចង់បាន ហើយអ្នកដឹកនាំក្នុងបណ្តាប្រទេសនីមួយៗខិតខំប្រឹងប្រែងរិះរកគ្រប់មធ្យោបាយ ដើម្បីឱ្យប្រទេសរបស់ខ្លួនទទួលបាននូវការអភិវឌ្ឍន៍គ្រប់វិស័យ។ ដោយឡែកនៅប្រទេសកម្ពុជាវិញហេតុអ្វីបានជាប្រជាពលរដ្ឋក្រីក្រភាគច្រើន ទាំងនៅទីក្រុង និងជនបទ តែងតែមានការភ័យខ្លាច និងព្រួយបារម្ភយ៉ាងខ្លាំងចំពោះពាក្យថាអភិវឌ្ឍន៍នេះទៅវិញ? តើការអភិវឌ្ឍន៍ប្រទេសកម្ពុជា យើងបានធ្វើឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រទាំងនោះអ្វីខ្លះ? តើរាល់បញ្ហា និងសេចក្តីព្រួយបារម្ភរបស់ប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ដែលកើតចេញពីការអភិវឌ្ឍន៍នោះ ស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយើង បានដោះស្រាយរកយុត្តិធម៌ជូនពួកគាត់ដែរឬទេ?

រឿងពិតមួយបានកើតឡើង នៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បងស្រី ឈ្មោះ អ៊ុំ សុភី ជាគ្រូបង្រៀនម្នាក់នៅសាលាបឋមសិក្សាសូវង្ស និងប្រជាពលរដ្ឋរស់នៅទីនោះបានបំភ្លឺថា យើងខ្ញុំក៏ដូចជាប្រជាពលរដ្ឋ ខ្មែរដទៃទៀតដែរ គឺតែងតែចង់បានសេចក្តីសុខសប្បាយ សេចក្តីរីកចំរើន និងរស់នៅក្នុងសង្គមនីតិរដ្ឋមួយ ដែលមានយុត្តិធម៌ គោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។ បន្ទាប់ពីរបបប្រល័យពូជសាសន៍រលំរលាយទៅ គ្រួសាររបស់យើងខ្ញុំបានមកតាំងទីលំនៅក្នុងភូមិខាងលើ និងកាន់កាប់ដីស្រែបង្កបង្កើនផល ព្រមទាំងចិញ្ចឹមសត្វ ដូចជា គោ ក្របី ជ្រូក មាន់ទា និងមុខរបរផ្សេងៗទៀត ដើម្បីចិញ្ចឹមជីវិតដោយសុខសាន្តក្រោមកិច្ចការពារ និងមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋាន គ្មានបុគ្គលណាម្នាក់រារាំង ឬរំខានឡើយ ដោយយើងខ្ញុំអាចរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ និងអាចឱ្យកូនៗទៅរៀនបាន។

ប៉ុន្តែឥឡូវនេះសេចក្តីសុខសាន្តរបស់យើងខ្ញុំ ត្រូវបានបាត់បង់អស់ហើយ ផ្ទុយទៅវិញជួបតែសេចក្តីភ័យខ្លាច និងទុកកង្វល់រៀងរាល់ថ្ងៃ ចាប់តាំងពីវត្តមានក្រុមហ៊ុន KDC International នៅក្នុងភូមិរបស់យើងខ្ញុំ។ ក្រុមហ៊ុននេះ បានរំលោភយកដីភូមិ និងដីស្រែរបស់យើងខ្ញុំ ដោយប្រើប្រព័ន្ធតុលាការដើម្បីចាប់ខ្លួនតំណាងរបស់យើងខ្ញុំដាក់គុកទៀតផង។ កន្លងមក យើងខ្ញុំបានរួមគ្នាដាក់ពាក្យបណ្តឹងចូលទៅគ្រប់ស្ថាប័នពាក់ព័ន្ធសុំឱ្យជួយអន្តរាគមន៍ដោះស្រាយរកយុត្តិធម៌ ប៉ុន្តែជាលទ្ធផលពុំទាន់មានដំណោះស្រាយនៅឡើយ។ ចំណែកឯខាងក្រុមហ៊ុនវិញ បានប្រើប្រាស់អំណាច និងឥទ្ធិពលរបស់ខ្លួនឈូសបំផ្លាញផ្ទះរបស់យើងអស់ចំនួន១៤ខ្នង ដោយគ្មានសំណងអ្វីឡើយ និងប្រើប្រាស់គ្រឿងចក្រ លើកជាទំនប់ដីកប្រឡាយហ៊ុមព័ទ្ធយកដីរបស់យើង និងមិនឱ្យយើងខ្ញុំចូលធ្វើស្រែបង្កបង្កើនផល ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃឡើយ។

បច្ចុប្បន្ននេះ ក្រុមហ៊ុនបានឈូសឆាយរៀបចំដោយពុះជាប្លង់ៗលើដីស្រែទំនាស់នោះ ទៅតាមគម្រោងផែនការរបស់គេហើយ រីឯប្រជាពលរដ្ឋយើងខ្ញុំវិញ កំពុងជួបនូវបញ្ហាជាច្រើន ដូចជា បាត់បង់ដីធ្លី គ្មានដីធ្វើស្រែ ដែលជាអាយុជីវិតរបស់យើងខ្ញុំ បាត់បង់ការងារនៅក្នុងសហគមន៍ កំពុងប្រឈមមុខនឹងភាពក្រីក្រគ្មានលុយព្យាបាលជំងឺ ខ្វះស្បៀងអាហារ សំលៀកបំពាក់ និងទីជំរក មួយភាគធំបានធ្វើចំណាកស្រុក ក្មេងស្រីខ្លះបានទៅធ្វើការបំរើតាមផ្ទះ ខ្លះធ្វើការស៊ីឈ្នួលគេនៅព្រំដែនខ្មែរ-ថៃ ប្រឈមមុខនឹងការជួញដូរផ្សេងៗ ពិសេសស្ត្រី រីឯកុមារកំពុងបោះបង់ការសិក្សា ដោយសារក្រុមគ្រួសារគ្មានប្រាក់ចំណូល ពុំមានលទ្ធភាពផ្គត់ផ្គង់ការសិក្សា លើសពីនេះយើងខ្ញុំមានការភ័យខ្លាចនឹងទទួលការគំរាមកំហែងពីសំណាក់ភាគីទំនាស់ទៀតផង។



ទីតាំងដីទំនាស់នៅភូមិឡពាង

បើតាមលទ្ធផលនៃការស៊ើបអង្កេតរបស់អង្គការសង្គមស៊ីវិលបានបង្ហាញថា ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ ឆ្នាំ១៩៨១ ប្រជាពលរដ្ឋនៅក្នុងភូមិទាំងអស់គ្នាបានប្រកបមុខរបរធ្វើស្រែចំការជាក្រុមសាមគ្គី លុះដល់ឆ្នាំ១៩៨២ ទើបរដ្ឋអំណាចបានបែងចែងដីនោះឱ្យទៅតាមក្រុមគ្រួសារនីមួយៗ។ ពួកគាត់បានកាន់កាប់រហូតមកដោយគោរពទៅតាមលក្ខខ័ណ្ឌនៃច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែពុំមានប័ណ្ណកម្មសិទ្ធិទេ។ បើតាមរបាយការណ៍របស់ លោក ថៃ ហ៊ី ជាឈ្មួញកណ្តាលទិញដីឱ្យក្រុមហ៊ុននោះ បានបញ្ជាក់ថា នៅអំឡុងឆ្នាំ១៩៩៦ និង ឆ្នាំ១៩៩៧ លោកបានឱ្យក្រុមលោក គុច បៀន មេភូមិ ឡពាង និង លោក ឡុំ ឡី មេភូមិបឹងកក់ ជាអ្នកទិញដីពីអ្នកភូមិបានសរុបចំនួនតែ ១៩៥,៤៦ហិកតា ប៉ុន្តែបើតាមក្រុមហ៊ុន បង្ហាញពីប័ណ្ណកម្មសិទ្ធិវិញដីសរុបរបស់ក្រុមហ៊ុនមានរហូតដល់ចំនួន ៥២២ហិកតា ឯណ្ណោះ។ នៅឆ្នាំ២០០៧ ភាគីក្រុមហ៊ុនបានយកគ្រឿងចក្រ ទៅជីកដីកាយជាប្រឡាយ ធ្វើជាទំនប់ហ៊ុមពទ្ធ័ដីទាំងនោះ។ នៅអំឡុងពេលនោះដែរក្រុមប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ចំនួន ១០៨គ្រួសារ ក្នុងនោះស្ត្រីជាមេគ្រួសារចំនួន៣០នាក់ នៅឃុំតាជេស បានប្តឹងតវ៉ាទៅអាជ្ញាធរមូលដ្ឋាន អាជ្ញាធរខេត្ត និងស្ថាប័នពាក់ព័ន្ធនានាជាច្រើនទៀត ទាមទារដីទំហំ១៨៤ហិកតា ប៉ុន្តែពុំទាន់មានដំណោះស្រាយនៅឡើយផ្ទុយទៅវិញផ្ទះសម្បែងរបស់ប្រជាពលរដ្ឋចំនួន ១៤ខ្នង ត្រូវបានក្រុមហ៊ុនឈូសបំផ្លាញដោយគ្មានសំណង។ មានតំណាងប្រជាពលរដ្ឋខ្លួនចំនួន៦នាក់ហើយ (ស្ត្រី២នាក់) ត្រូវបានគេចាប់ខ្លួនឃុំក្នុងពន្ធនាគារ។ ដោយមានការភ័យខ្លាចចំពោះ ការគំរាមកំហែងពីសំណាក់ក្រុមហ៊ុន និងភាពក្រីក្រ ប្រជាពលរដ្ឋមួយចំនួន បានបោះបង់បណ្តឹងឈប់ប្តឹង



សកម្មភាពស៊ើបអង្កេតរបស់អង្គការសង្គមស៊ីវិល



ប្រព័ន្ធប្រឡាយព្រំដីរបស់ក្រុមហ៊ុន

បច្ចុប្បន្ននេះមានតែប្រជាពលរដ្ឋចំនួន ៦៤គ្រួសារ ក្នុងនោះស្ត្រីជាមេគ្រួសារចំនួន ២០នាក់ នៅភូមិឡពាងកំពុងបន្តបណ្តឹងទាមទារដីចំនួន១៤៥ហិកតា។

ការអូសបន្លាយពេលក្នុងការដោះស្រាយបញ្ហាទំនាស់ដីធ្លីនេះ គឺជាកំហុសនីតិវិធីដោះស្រាយទំនាស់ក្នុងការអនុវត្តច្បាប់ ដែលបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងផ្ទុយពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

## សំណូមពរ

- អាជ្ញាធរមានសមត្ថកិច្ចគួរតែលើកយកបណ្តឹងទាមទារដីធ្លីរបស់ប្រជាពលរដ្ឋមកដោះស្រាយឱ្យបានឆាប់រហ័សប្រកបដោយភាពយុត្តិធម៌។
- តុលាការគួរតែបង្អង់រឿងក្តីព្រហ្មទណ្ឌសិន រង់ចាំលទ្ធផលនៃការដោះស្រាយរឿងរដ្ឋប្បវេណី (ដីធ្លី) ថាតើដីទំនាស់នោះជាកម្មសិទ្ធិរបស់ភាគីណាពិតប្រាកដ។
- គួរតែដោះលែងតំណាងប្រជាពលរដ្ឋដែលកំពុងជាប់ពន្ធនាគារពាក់ព័ន្ធនឹងទំនាស់ដីធ្លីនេះ ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន និងបញ្ឈប់ការគំរាមកំហែងចាប់ខ្លួនប្រជាពលរដ្ឋជាបន្តទៅទៀត។

អត្ថបទដោយៈ ក្រុមការងារកម្មវិធីដីធ្លី និង ជីវភាព
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

# តើដីសម្បទានសេដ្ឋកិច្ចពិតជាផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្រីក្រឬ?

ក្រុមហ៊ុនអង្គរស៊ូហ្គ័រ គឺជាក្រុមហ៊ុនក្នុងស្រុកមួយ ដែលបានធ្វើការវិនិយោគជាមួយនឹងភាគទុនិកប្រទេសថៃ ដែលបានធ្វើការអភិវឌ្ឍន៍នៅតំបន់ច្រកវាលស្នាច់ខាងវារីអគ្គិសនី និង ទឹកស្អាត លើសពីនេះទៅទៀត ក្រុមហ៊ុននេះបានធ្វើការវិនិយោគទៅលើដំណាំអំពៅ ដែលមានផ្ទៃដីសរុបប្រមាណ ១០៥៧៣ ហិចតា ដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទក្នុងគោលបំណងដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និង លក់ចេញទៅក្រៅប្រទេស។ ក្រុមហ៊ុននេះ បានធ្វើពាក្យស្នើសុំទៅនាយករដ្ឋមន្ត្រី តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅថ្ងៃទី០៨ ខែមិនា ឆ្នាំ២០០៧




ការដ្ឋានក្រុមហ៊ុនអង្គរស៊ូហ្គ័រ

ហើយចាប់ផ្តើមបើកយុទ្ធនាការឈូសឆាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ បណ្តាលឱ្យប៉ះពាល់ដល់ដីប្រជាពលរដ្ឋ ជាង៦៥២៣ហិតា នៅតំបន់ឈូកមាស និងក្តាន់ធំ ដោយពុំទាន់បានដោះស្រាយផលប៉ះពាល់នោះឡើយ។ នេះជាមូលហេតុធ្វើឱ្យប្រជាពលរដ្ឋកើតទុក្ខមិនសុខចិត្តចំពោះវត្តមានរបស់ក្រុមហ៊ុននេះ។

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ កងកំលាំងចំរុះ រួមមានទាហានប៉ូលីស និងប៉េអឹមខេត្តឧត្តរមានជ័យរាប់សិបនាក់ ប្រដាប់ដោយអាវុធបានប្រព្រឹត្តអំពើហិង្សាបង្ខំប្រជាពលរដ្ឋចំនួន១១៥គ្រួសារ (ស្រ្តីជាមេគ្រួសារចំនួន៣៤នាក់) ឱ្យចេញពីលំនៅដ្ឋានរបស់ពួកគាត់ដែលស្ថិតនៅភូមិអូរបាត់មាន់ ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ដើម្បីយកដីទាំងនោះប្រគល់ជូនក្រុមហ៊ុនអង្គរស៊ូហ្គ័រធ្វើការវិនិយោគដាំដំណាំអំពៅ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារកំពុងរស់នៅក្រោមកំដៅថ្ងៃ និង ដំណក់ទឹកភ្លៀង បន្ទាប់ពីអាជ្ញាធរខេត្តបញ្ជាឱ្យគ្រឿងចក្រឈូសឆាយ និង ដុតបំផ្លាញផ្ទះរបស់ពួកគាត់។ សំរែកទ្រហោយំរបស់ប្រជាពលរដ្ឋទាំងនោះ អំពាវនាវសុំការអន្តរាគមន៍ពីអង្គការជាតិ និង អន្តរជាតិ ជាពិសេសសុំការអន្តរាគមន៍ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ឈប់សកម្មភាពរំលោភសិទ្ធិមនុស្សសិទ្ធិលំនៅដ្ឋាន។ អ្នកភូមិបាននិយាយថា"នៅពេលបាត់បង់ផ្ទះសំបែង និងដីធ្លីហើយ គ្មានអ្វីជាទីពឹងទៀតទេ"។ ករណីនេះត្រូវបាន មន្ត្រីអង្គការសង្គមស៊ីវិលចុះទៅដល់ទីកន្លែងកើតហេតុប្រមូលព័ត៌មាន និងបានធ្វើអន្តរាគមន៍ទៅអាជ្ញាធរខេត្តឧត្តរមានជ័យ ដើម្បីជួយដោះស្រាយរកយុត្តិធម៌ស្នើសុំឱ្យបញ្ឈប់ការតាមរកចាប់ខ្លួនតំណាងប្រជាពលរដ្ឋសុំឱ្យផ្តល់ដីសម្បទានសង្គមកិច្ចសមរម្យ ដែលអាចឱ្យពួកគាត់ ប្រកបរបរចិញ្ចឹមជីវិតបាន។ ទន្ទឹមនឹងកិច្ចខំប្រឹងប្រែងនេះ គេក៏បានជួបនូវបញ្ហាមួយចំនួន ដូចជាក្រុមហ៊ុនហាមឃាត់ក្រុមមន្ត្រីសង្គមស៊ីវិលមិនឱ្យចូលទៅយកព័ត៌មានដល់កន្លែងកើតហេតុ។ ក្រុមប្រជាពលដ្ឋទទួលរងផលប៉ះពាល់បានបញ្ជាក់ថា មានប៉ូលីស ប៉េអឹម និង ទាហានរាប់សិបនាក់ ប្រដាប់ដោយអាវុធ បានគំរាមកំហែង ដុតលំនៅដ្ឋាន វាយដំ និង ធ្វើទារុណកម្មលើប្រជាពលរដ្ឋបង្ខំឱ្យចាកចេញពីដីទំនាស់ ដោយពុំមានការជូនដំណឹងឱ្យដឹងជាមុនឡើយ ដែលបណ្តាលឱ្យប្រជាពលរដ្ឋវ័យចំណាស់ៗមួយចំនួនបាក់ស្មារតីធ្លាក់ខ្លួនឈឺ ហើយពុំមានលទ្ធិភាពទៅព្យាបាលជំងឺនៅមន្ទីពេទ្យខេត្ត។ ជាមួយគ្នានេះសមត្ថកិច្ចបានចាប់តំណាងអ្នកភូមិចំនួន ០៣ នាក់ និង វាយអ្នកភូមិម្នាក់ទៀត បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ(បាក់ដៃ)។ តំណាង




ជនរងគ្រោះកំពុងអំពាវនាវសុំឱ្យជួយដោះស្រាយ




ផ្ទះប្រជាជនដែលត្រូវបានក្រុមហ៊ុនដុតបំផ្លាញក្នុងភូមិអូរបាត់មាន់

អ្នកភូមិខាងលើនេះត្រូវបានតុលាការខេត្តសៀមរាប ធ្វើការឃុំខ្លួននៅពន្ធនាគារ ចំណែកអ្នកភូមិមួយចំនួនទៀតបានរត់គេចខ្លួន។ បើតាមការបញ្ជាក់របស់អ្នកភូមិបង្ហាញថា "ពួកគាត់បានរស់នៅលើដីទំនាស់នេះតាំងពីឆ្នាំ២០០៣ ដោយមានការទទួលស្គាល់ពីមេភូមិ និង មេឃុំ មានប្រជាពលរដ្ឋក្រីក្រមករស់នៅតំបន់នេះជាបន្តបន្ទាប់ ដោយសារមានការផ្តល់ដីសម្បទានសង្គមកិច្ចពីមេភូមិ (រហូតកើនដល់ចំនួន ២១៤ គ្រួសារក្នុងនោះមានស្ត្រីជាមេគ្រួសារចំនួន ៦៣នាក់ និង ដីប្រហែល ៤០ហិកតា)"។

បន្ទាប់ពីព្រឹត្តិការណ៍បណ្តេញចេញ មានប្រជាពលរដ្ឋមួយចំនួនត្រូវបានបែកបាក់គ្រួសារ ព្រាត់ប្តីប្រពន្ធ និង កូន ពុំទាន់បានជួបជុំគ្នាវិញនៅឡើយ។ បច្ចុប្បន្នប្រជាពលរដ្ឋទាំងនោះ កំពុងប្រឈមមុខនឹងការខ្វះស្បៀងអាហារ ទឹកស្អាត ទីជំរក និង មានជំងឺគ្រុនចាញ់ រាគរូស ពុំមានថ្នាំព្យាបាលគ្រប់គ្រាន់ និង ប៉ះពាល់ដល់ការសិក្សារបស់កុមារ។



ជនរងគ្រោះដោយការវាយដំ

បន្ទាប់ពីមានបណ្តឹងរបស់ប្រជាពលរដ្ឋ និងការអន្តរាគមន៍របស់អង្គការសង្គមស៊ីវិល អាជ្ញាធរខេត្តឧត្តរមានជ័យ បានបង្កើតគណៈកម្មការដោះស្រាយវិវាទដីធ្លីនេះ ដោយធ្វើជាបីដំណាក់កាលធំៗគឺ ៖

- ទី១៖ ប្រជាពលរដ្ឋចំនួន ៣៥គ្រួសារ ដែលគេសិក្សាថាមានដី និង ផ្ទះនៅតាមភូមិផ្សេងៗក្បែរនោះ គេនឹងដឹកជញ្ជូនឱ្យទៅនៅកន្លែងដើមវិញ។
- ទី២៖ ប្រជាពលរដ្ឋចំនួន ១១៥គ្រួសារ នៅភូមិអូរបាត់មាន់ពិតប្រាកដអាជ្ញាធរនឹងចែកដីសម្បទានសង្គមកិច្ច តាមគោលការណ៍របស់សាលាខេត្តនៅតំបន់ដកហូតនៅវាលថែងម៉ែង ចំនួន ៤០០ហិតា។
- ទី៣៖ ប្រជាជនដែលស្ថិតនៅខេត្តឆ្ងាយៗ អាជ្ញាធរនឹងដឹកបញ្ជូនទៅខេត្តទាំងនោះវិញ ប៉ុន្តែបើគេសិក្សាថា ពួកគាត់ពិតជាក្រីក្រគ្មានដីប្រាកដមែននឹងទទួលបានដីសម្បទានសង្គមកិច្ចតាមគោលការណ៍របស់ខេត្ត។

ជាក់ស្តែងគោលការណ៍ផ្តល់ដីសម្បទានសង្គមកិច្ច(ដីភូមិ ៣០ ម៉ែត្រ X ៥០ម៉ែត្រ និងដីស្រែ១ហិកតា) នេះត្រូវបានប្រជាពលរដ្ឋប្រមាណចំនួន៧០ភាគរយ សំរេចចិត្តយល់ព្រមទទួលយក។



ប្រជាជនដែលត្រូវគេបានជំលៀសចេញពីភូមិអូបាត់មាន់ ដែលមកស្នាក់នៅវត្តគោកភ្នក

ក្នុងនាមជារដ្ឋភាគីរបស់អង្គការសហប្រជាជាតិ ដែលបានហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិកិច្ចព្រមព្រៀងទីក្រុងប៉ារីស និង លើលិខិតតូបករណ៍អន្តរជាតិផ្សេងៗទៀត និង មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថាខ្លួននឹងគោរពការពារ និង លើកកំពស់សិទ្ធិមនុស្ស។ ក្នុងករណីនេះ ប្រជាពលរដ្ឋរបស់ខ្លួនកំពុងជួបបញ្ហាខ្វះខាតដីធ្លី និងពុំមានលទ្ធភាពទ្រទ្រង់ជីវភាពគ្រួសារឱ្យសមទៅនឹងមនុស្សជាតិ នេះជាកាតព្វកិច្ចរដ្ឋាភិបាលកម្ពុជា ត្រូវតែបំពេញជូនប្រជាពលរដ្ឋរបស់ខ្លួន ដើម្បីអាចរស់មានលក្ខណៈសមរម្យភាពជាមនុស្ស ហើយដាច់ខាតមិនត្រូវប្រព្រឹត្តអំពើហិង្សា អមនុស្សធម៌

និង បណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំនោះទេ។

ដូច្នេះក្នុងនាមអង្គការសង្គមស៊ីវិល និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមមានជាសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចដូចខាងក្រោម៖

- សូមជួយដោះស្រាយបញ្ហាទំនាស់ដីធ្លីដោយយុត្តិធម៌ ព្រមទាំងផ្តល់ដីសម្បទានសង្គមកិច្ចរួមមាន ដីលំនៅដ្ឋាន និង ដីកសិកម្ម ដែលអាចឱ្យពួកគាត់ប្រកបអាជីវកម្មដោះស្រាយជីវភាពបាន។
- សូមឱ្យមានការដោះលែងជនជាប់ចោទដោយសារបញ្ហាដីធ្លីឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន និងបញ្ឈប់ការតាមរកចាប់ខ្លួនប្រជាពលរដ្ឋបន្តទៀត។
- សូមផ្តល់ជំនួយសង្គ្រោះបន្ទាន់ជូនប្រជាពលរដ្ឋទាំងនេះ ដែលកំពុងប្រឈមនឹងការខ្វះខាតស្បៀង។

*អត្ថបទដោយ៖ លោក ប្លុង ផាត*
*មន្ត្រីកម្មវិធីសមាគមន៍អភិវឌ្ឍន៍កុមារ*
*គណៈកម្មាធិការបណ្តាញជីវភាពអាស្រ័យព្រៃឈើ និង ចំការឈើដាំ*

# ក្រុមហ៊ុនពីរប្រឹងផ្តល់គ្នាដើម្បីដណ្តើមយកដីអ្នកភូមិ

ដី គឺជាអចលនវត្ថុមួយដ៏សំខាន់បំផុតសំរាប់បង្កបង្កើតផល និងជាប្រភពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ប្រមាណ ៧១ភាគរយ ដែលចំណូលរបស់ពួកគាត់ត្រូវបានទទួលពីសកម្មភាពកសិកម្ម។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ កំពុងបង្កឱ្យមានបញ្ហាជាច្រើន ដូចជាកង្វះខាតដីកសិកម្ម ការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ ភាពគ្មានដីកសិកម្ម ការកាប់រានដីខុសច្បាប់ និងជម្លោះដីធ្លីមានសភាពកាន់តែអាក្រក់ឡើងៗ ចាប់តាំងពីប្រទេសកម្ពុជាប្រកាន់យកទីផ្សារសេរីនៅដើមឆ្នាំ១៩៩០។ ជម្លោះដីធ្លី និងការគ្មានដីធ្វើកសិកម្ម អាចកើតឡើងខណៈពេលដែលប្រទេសកម្ពុជាបានជំរុញវិស័យឯកជន និងការធ្វើឱ្យមានការវិនិយោគកើនឡើង។ ទន្ទឹមនឹងបញ្ហាដ៏ច្រើននេះរាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការដោះស្រាយដោយបានបង្កើតច្បាប់ជាច្រើន ដូចជាច្បាប់ភូមិបាល ច្បាប់ព្រៃឈើច្បាប់ស្តីពីការការពារបរិស្ថាន និងអនុក្រិត្យផ្សេងៗដាក់ឱ្យប្រើប្រាស់ថែមទាំងគោលនយោបាយដីធ្លី និងអនុសាសន៍មួយចំនួនទៀត ដើម្បីឱ្យអនុវត្តក្នុងគោលបំណងរួមចំណែកដោះស្រាយទំនាស់ដីធ្លី ការពារធនធានធម្មជាតិ និងកាត់បន្ថយភាពក្រីក្រ។




ទីតាំងដីទំនាស់នៅភូមិព្រែកជីក

ទោះជាយ៉ាងនេះក្តី យើងក៏ឃើញចំណុចអវិជ្ជមានមួយចំនួនរួមមានអំពើហិង្សា ការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំ ការកាប់បំផ្លាញព្រៃឈើ និងការរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋពីសំណាក់អ្នកមានអំណាច និងក្រុមហ៊ុនមួយចំនួន។

ប្រជាពលរដ្ឋចំនួន ៤៣ គ្រួសារ ក្នុងនេះស្ត្រីមេម៉ាយជាមេគ្រួសារមានចំនួន៤នាក់ រស់នៅភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ជាប់បណ្តោយផ្លូវលេខ៤៨ កំពុង មានបញ្ហាយ៉ាងខ្លាំង ដោយដីធ្លី ដំណាំ ឈើផ្លែ និងលំនៅដ្ឋានរបស់ពួកគាត់ដែលបានកាន់កាប់គ្រប់គ្រង ចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ កំពុងត្រូវបានរំលោភយកដោយក្រុមហ៊ុនឯកជនពីរឈ្មោះគ្នាប្ដឹងដណ្តើមយក។

ដីទំនាស់នេះចំនួនប្រហែល ២០០ហិកតា ជាប្រភេទដីកសិកម្ម និងលំនៅដ្ឋាន ដោយប្រជាពលរដ្ឋបានសង់ផ្ទះ ដាំដំណាំធំៗ ដូចជា ដូង ក្រូច ស្វាយ ខ្នុរ ស្វាយចន្ទី ចេក ល្ហុង និង បង្កបង្កើនផលស្រូវ អំពៅ ពោត សណ្តែក ដំឡូង ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ។

នៅឆ្នាំ១៩៧៩-១៩៩៥ តំបន់នេះ ជាតំបន់អសន្តិសុខ



សកម្មភាពប្រជាពលរដ្ឋចូលរួមការអនុវត្តសាលដីកាតុលាការកំពូល

ត្រូវបានគ្រប់គ្រងដោយកងកំលាំងខ្មែរក្រហម។ ប្រជាពលរដ្ឋ បានចូលទៅធ្វើស្រែចំការបាននៅរដូវវស្សា និង អាស្រ័យផលអនុផលព្រៃឈើ ប៉ុន្តែពុំមានការតាំងទីលំនៅនៅតំបន់នោះទេ។ បន្ទាប់ពីកំលាំងខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៦-១៩៩៧ ប្រជាពលរដ្ឋប្រមាណ ៤៥គ្រួសារ ស្ត្រីមេម៉ាយជាមេគ្រួសារចំនួន៥នាក់ បានចូលទៅតាំងលំនៅដ្ឋានជាអចិន្ត្រៃយ៍នៅតំបន់នោះ ដោយមានការបែងចែកដីគ្នាកាន់កាប់(ទទួលស្គាល់ពីអាជ្ញាធរភូមិឃុំ)។ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៦ លោកចៅក្រម និងក្រឡាបញ្ជីតុលាការកំពូលបានចុះទៅវាស់វែងដីភូមិ និងដីស្រែចំការរបស់ប្រជាពលរដ្ឋភូមិព្រែកជីក ទើបពួកគាត់ដឹងថា ក្រុមហ៊ុន លោក សុខ ហុង និង លោក ហេង ហ៊ុយ បានប្តឹងគ្នាដណ្តើមយកដីរបស់ពួកគាត់។ ប្រជាពលរដ្ឋចំនួន ៦៣ គ្រួសារបានដាក់បណ្តឹងចូលជាតតីជន(ភាគីទី៣) ទៅតុលាការកំពូល ប៉ុន្តែរហូតដល់ពេលនេះ ពុំទាន់មានចំណាត់ការអ្វីមួយឡើយចំពោះបណ្តឹងរបស់ប្រជាពលរដ្ឋទាំងនោះ គឺតុលាការចាត់ការតែរឿងក្តីរវាង លោក សុខ ហុង និង លោក ហេង ហ៊ុយ តែប៉ុណ្ណោះ។ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧ លោក សុខ ហុង បានដាក់ពាក្យបណ្តឹងទៅតុលាការកំពូល ចោទប្រកាន់ប្រជាពលរដ្ឋចំនួន ០៦ គ្រួសារ ថានៅលើដីទំនាស់។ តុលាការបានចេញបញ្ជាឱ្យបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន ០៦គ្រួសារ ក្នុងនោះផ្ទះរបស់ប្រជាពលរដ្ឋចំនួន ០៣គ្រួសារ ត្រូវវាយបំផ្លាញ ហើយប្រជាពលរដ្ឋបានប្រមូលគ្នាតវ៉ាយ៉ាងខ្លាំង ដើម្បីបញ្ឈប់សកម្មភាព និងសុំការអន្តរាគមន៍ពីក្រសួងយុត្តិធម៌។ ស្របពេលជាមួយគ្នានេះ តុលាការខេត្តកោះកុង បានបញ្ជាឱ្យប្រជាពលរដ្ឋចំនួន ៩គ្រួសារ រុះរើផ្ទះចេញពីដីរបស់ខ្លួន។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន លោក ហេង ហ៊ុយ បានយកគ្រឿងចក្រ ឈូសឆាយដីព្រៃក្បែរចំការរបស់អ្នកភូមិ រួចឈូសបំផ្លាញដីស្រែចំការ ប្រជាពលរដ្ឋ ភូមិឈូក និងព្រែកជីក បណ្តាលឱ្យមានការប្រមូលគ្នាតវ៉ាដាក់បណ្តឹងទៅក្រសួងយុត្តិធម៌។ ទោះបីជា មានលិខិតពីក្រសួងយុត្តិធម៌បញ្ជាឱ្យក្រុមហ៊ុនផ្អាកសកម្មភាពឈូសឆាយក៏ក្រុមហ៊ុនមិនគោរពដែរ គឺនៅតែបន្តឈូសឆាយយកដីរបស់អ្នកភូមិដដែល។ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ តុលាការកំពូលបានបើកសវនាការជំនុំជំរះរឿងក្តីទំនាស់ដីធ្លីរវាង លោក ហេង ហ៊ុយ និង លោក សុខ ហុង ដោយមិនបានលើកនិយាយ ឬពិចារណាពីបណ្តឹងចូលជាតតីជនរបស់ប្រជាពលរដ្ឋទេ។ តុលាការបានវិនិច្ឆ័យសេចក្តីៈ

១-ប្រគល់ដីទំនាស់ដែលមានទីតាំងស្ថិតនៅភូមិឈូក ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យទៅដើមបណ្តឹងគឺ លោក ហេង ហ៊ុយ។

២-ប្រគល់ដីទំនាស់ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីស្ថិតក្នុងភូមិសាស្ត្រភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យទៅចុងចម្លើយគឺ លោក សុខ ហុង។

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ លោកព្រះរាជអាជ្ញារងអមតុលាការខេត្តកោះកុង បានប្រកាសថា "ថ្ងៃនេះយើងអនុវត្តសាលដីការបស់តុលាការកំពូលតាមសំណើរបស់លោក ហេង ហ៊ុយ ទៅលើតែដីស្ថិតនៅភូមិឈូក ឃុំជីខលើ តែប៉ុណ្ណោះ មិនប៉ះពាល់ដីភូមិព្រែកជីក ឃុំជីខក្រោមទេ និងពុំមានការរុះរើផ្ទះសំបែងរបស់ប្រជាពលរដ្ឋណាទេ"។ ប៉ុន្តែនៅពេលចុះអនុវត្តវាស់ដីជាក់ស្តែងធ្វើនៅលើភូមិសាស្ត្រភូមិព្រែកជីកទៅវិញដែលជាន់គ្នាទៅនឹងដីក្រុមហ៊ុន សុខ ហុង ទទួលបានតាមអំណាចសាលដីកា។ សហគមន៍ទទួលរងផលប៉ះពាល់កំពុងមានការព្រួយបារម្ភចំពោះការបាត់បង់ផ្ទះសំបែង ដំណាំដីលំនៅដ្ឋាន ដីកសិកម្ម ដីកន្លែងផ្សេងសំរាប់សង់លំនៅដ្ឋានជីវភាពរស់នៅព្រមទាំងការរៀនសូត្ររបស់កូនចៅ និងការគំរាមកំហែង ឬការបណ្តេញចេញដោយបង្ខំដោយគ្មានការផ្តល់សំណងសមរម្យជាមុន។

ការរំលោភយកដី និងការបណ្តេញចេញដោយបង្ខំនេះជាអំពើមួយរំលោភច្បាប់ជាតិ និងច្បាប់អន្តរជាតិ រួមមានច្បាប់ភូមិបាលឆ្នាំ២០០១ ដូចមានចែងក្នុងមាត្រា៥ មាត្រា៣០ មាត្រា៣១ និង មាត្រា៣៨ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានចែងក្នុងមាត្រា៣១ កតិកាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ មាត្រា១។

ហេតុដូច្នេះតុលាការកំពូលគួរតែចាត់វិធានការដោះស្រាយលើបណ្តឹងចូលជាតតីជនរបស់ប្រជាពលរដ្ឋ និង សើរើរឿងក្តីរដ្ឋប្បវេណីនេះឡើងវិញ ដោយហេតុថាសាលដីកានេះ ពុំច្បាស់លាស់មិនអាចយក

អនុវត្តបានពីព្រោះសេចក្តីសំរេចរបស់សាលដីកានេះ គឺប្រគល់ដីឱ្យទៅភាគីទាំងពីរនៅភូមិផ្សេងៗគ្នា (ភូមិឈូក និង ព្រៃកជីក) ប៉ុន្តែនៅពេលអនុវត្តជាក់ស្តែងវាស្ថិតនៅលើភូមិសាស្ត្រជាន់គ្នាតែមួយគឺភូមិព្រៃកជីក។ អាជ្ញាធរមានសមត្ថកិច្ច ឬ ក្រុមហ៊ុន គួរតែដោះស្រាយសំណងសមរម្យ និង យុត្តិធម៌ជូនប្រជាពលរដ្ឋជាមុនសិន មុននឹងធ្វើការឈូសឆាយដីទំនាស់នេះ។

*អត្ថបទ និង រូបភាពដោយៈ បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍*

# ប្រជាជនក្រីក្ររស់នៅតាមបណ្តោយផ្លូវជាតិលេខ ៧៨ កំពុងទទួលរងនូវផលប៉ះពាល់

សព្វថ្ងៃនេះ ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និងសង្គម កំពុងត្រូវបានយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ក្នុងគោលបំណង ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋហើយក៏ជាផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអណត្តិទី៤ បានប្តេជ្ញាផងដែរ។ គំរោងអភិវឌ្ឍន៍នានា ត្រូវបាននឹងកំពុងសិក្សាស្ទើរគ្រប់ទីកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានទាំងគំរោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ កម្ពុជា ជាប្រទេសមួយដែលមានខឿនសេដ្ឋកិច្ចពឹងផ្អែកស្ទើរតែទាំងស្រុងលើវិស័យកសិកម្ម និងធនធានធម្មជាតិ ដែលបច្ចុប្បន្នធនធានធម្មជាតិស្ទើរតែទាំងស្រុង ត្រូវបានគេយកមកប្រើប្រាស់ និងអភិវឌ្ឍន៍តាមទំរង់រូបភាពផ្តល់ដីសម្បទាន ព្រៃសម្បទាន ការជីករករ៉ែក្រោមដី និងការកសាងទំនប់វារីអគ្គីសនីជាដើម ដែលប្រតិបត្តិការដោយក្រុមហ៊ុនឯកជនក្នុងស្រុក និងក្រៅប្រទេស។ ការធ្វើអាជីកម្មលើធនធានធម្មជាតិទាំងនេះ បានផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិទន្ទឹមគ្នា ហើយដែលភាគច្រើនអ្នកដែលទទួលរងនូវគុណវិបត្តិ គឺជាប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ស្រុក។ គំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីសេសានក្រោម ២ ជាគំរោងទំនប់ខ្នាតធំមួយក្នុងខេត្តស្ទឹងត្រែង ត្រូវបានទទួលសិទ្ធិសំរាប់ការសិក្សា និងសាងសង់ដោយក្រុមហ៊ុនវៀតណាម ឈ្មោះ EVNI ដែលមានតំលៃជាទឹកប្រាក់ ៨១៦,២៣ លានដុល្លាអាមេរិក មានកំលាំងថាមពល ៤00 មេហ្គាវ៉ាត់ មានកំរិតកំពស់ខ្នងទំនប់ ៨៣ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ ឬប្រហែល ៤0 ម៉ែត្រ ខ្ពស់ជាងបាតទន្លេ និងមានទទឹងខ្នងលើ ៨ ម៉ែត្រ មានរយៈពេលសាងសង់ ៤ឆ្នាំ និងប្រតិបត្តិការ ៣0ឆ្នាំ (ជាប្រភេទគំរោងសាងសង់ប្រតិបត្តិ និងផ្ទេរ BOT) បានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសាងសង់ក្នុងគោលបំណងទាញយកថាមពលអគ្គិសនីមកប្រើប្រាស់នៅក្នុងតំបន់ជិតខាង និងលក់ទៅប្រទេសវៀតណាម សំរាប់ផលចំណេញសេដ្ឋកិច្ច។ គំរោងនេះ បានធ្វើឱ្យប្រជាពលរដ្ឋក្នុងតំបន់រាប់ពាន់គ្រួសារត្រូវផ្លាស់ប្តូរទីលំនៅ និងភូមិកររបស់ពួកគាត់ ព្រោះតែតំបន់នោះនឹងក្លាយទៅជាទីតាំងអាងស្តុបទឹកសំរាប់វារីអគ្គីសនី បន្ទាប់ពីទំបន់នេះត្រូវបានសាងសង់រួច។ មិនត្រឹមតែប្រជាពលរដ្ឋប៉ុណ្ណោះទេ ដែលប៉ះពាល់សូម្បីតែសត្វព្រៃឈើ ជីវចំរុះផ្សេងៗ និងផ្លូវជាតិលេខ ៧៨ ដែលតភ្ជាប់ពីខេត្តស្ទឹងត្រែងទៅកាន់ខេត្តរតនៈគីរី ក៏នឹងត្រូវលិចលង់មួយភាគធំដែរ។ ដើម្បីតភ្ជាប់ចរាចរខេត្តទាំងពីរឡើងវិញអ្នកអភិវឌ្ឍន៍គំរោង បានសំរេចធ្វើផ្លូវវាងថ្មីមានចំងាយ ៥៥ គីឡូម៉ែត្រ ដែលផ្លូវវាងនេះ ចាប់ផ្តើមត្រង់បង្គោលគីឡូម៉ែត្រលេខ ២៥ ត្រង់ចំនុចភូមិក្បាលច្រប់ និងបញ្ចប់នៅត្រង់បង្គោល គីឡូម៉ែត្រលេខ ៧៨ ត្រង់ចំនុចឃុំ ស្រែអង្គ្រង លើផ្លូវជាតិលេខ ៧៨ ដែលផ្លូវនេះនឹងកាត់ទន្លេស្រែពក ក្នុងភូមិសាស្ត្រខេត្តរតនៈគីរី។

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២00៩ រាជរដ្ឋាភិបាលកម្ពុជា និង ឯកអគ្គរដ្ឋទូតចិន បានអញ្ជើញទៅសម្ពោធបើកការដ្ឋានសាងសង់ និងស្តារឡើងវិញផ្លូវជាតិលេខ ៧៨ ពីអូរពងមាន់ទៅក្រុងបានលុង ខេត្តរតនៈគីរី មានចំងាយផ្លូវសរុប ១២១គីឡូម៉ែត្រ មានទទឹង ១១ម៉ែត្រ ក្រាលកៅស៊ូ ដែលទទួលម៉ៅការស្ថាបនាដោយក្រុមហ៊ុនចិន ឈ្មោះ សៀងហៃ។ ផ្លូវនេះត្រូវចំណាយថវិកាសរុប ៧៣,៣00,000 ដុល្លាសហរដ្ឋអាមេរិក ដែលជាកម្ចីឥណទានពីរដ្ឋាភិបាលចិន និងថវិកាបដិភាគ ៥% របស់រាជរដ្ឋាភិបាលកម្ពុជា និងចំណាយពេលសាងសង់ចំនួន ៤0ខែ។



ចំនុចផ្លូវវាងគីឡូម៉ែត្រ ២៥ ពីអូរពងមាន់ និងផ្លូវវាងតាមដានផ្លូវរទេះចាស់ ដែលនឹងមានការកាប់ព្រៃឈើទទឹងទំហំ៥០ម៉ែត្រ ប្រវែង ៥៥គីឡូម៉ែត្រ

## ផលប៉ះពាល់ដោយផ្ទាល់:

ដោយសារតែផ្លូវវាងថ្មីនេះ ត្រូវសាងសង់កាត់តាមក្នុងព្រៃ ដែលជាដានផ្លូវរទេះចាស់ ដូចនេះមានផលប៉ះពាល់ដោយផ្ទាល់តិចតួច ដល់លំនៅដ្ឋាន និងដីស្រែរបស់ប្រជាពលរដ្ឋនៅឃុំក្បាលច្រប់ក្របីជ្រុំ និង ឃុំស្រែអង្រ្គង ដែលមានប្រជាពលរដ្ឋសរុបប្រហែល ៣៧០គ្រួសារ ស្ត្រីមេម៉ាយជាមេគ្រួសារ ១៦គ្រួសារ។ ប៉ុន្តែព្រៃឈើមួយភាគធំ នឹងត្រូវកាប់ដើម្បីបើកចំណីផ្លូវ(២៥ម៉ែត្រពីអ័ក្ស) មានចំងាយ ៥៥ គីឡូម៉ែត្រ ហើយប្រជាពលរដ្ឋរាប់ពាន់គ្រួសារផ្សេងទៀតនឹងត្រូវរើ លំនៅដ្ឋានដោយសារទឹកជំនន់នៅពេលដែលទំនប់ត្រូវបានសាងសង់។

អាជ្ញាធរឃុំស្រែអង្រ្គងបានឱ្យដឹងថា ភូមិនៅក្នុងឃុំនេះដែរ មានចំនួន៣ភូមិ គឺភូមិទី១ ទី២ និងទី៣ ដែលមានប្រជាពលរដ្ឋសរុប ជាង ៣៤០គ្រួសារ ស្ត្រីមេម៉ាយជាមេគ្រួសារ ១៦គ្រួសារ ប្រកបមុខរបរធ្វើស្រែ-ចំការ-រកត្រី និងខ្លះទៀតរកស៊ីដងជ័រទឹកនៅក្នុងព្រៃ ហើយប្រជាពលរដ្ឋទាំងនេះ នឹងត្រូវរើទៅសង់លំនៅដ្ឋានថ្មីនៅតាម បណ្តោយផ្លូវថ្មី ដែលពួកគាត់នឹងត្រូវទទួលបានដីទំហំ ៥០ម៉ែត្រ x ២០ ម៉ែត្រ សំរាប់សង់លំនៅដ្ឋាន ដែលជាប្រភេទដីស្រែស្ថិតនៅឃុំស្រែ អង្រ្គង មានចំងាយប្រហែល ៣គីឡូម៉ែត្រ ពីទីតាំងចាស់ព្រោះ ភូមិចាស់នឹងត្រូវទឹកជន់លិចនៅរដូវវស្សា នៅពេលដែលទំនប់សាង សង់រួចរាល់ ឯចំណែកថវិកាឧបត្ថម្ភសំរាប់សង់លំនៅដ្ឋាន និងថ្លៃរុះរើ មិនទាន់មានការព័ត៌មានជាក់លាក់នៅឡើយទេ។ អាជ្ញាធរបញ្ជាក់ ទៀតថា ផ្លូវលេខ៧៨នេះ នឹងត្រូវស្ថាបនាកាត់វាលធំនៅក្រោយ ភូមិប្រហែល ៣គីឡូម៉ែត្រ ហើយប៉ះពាល់ដីស្រែ ៤ ទៅ ១០ ស្រែ។ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ដំណើរការឈូសឆាយផ្លូវនឹងត្រូវ ចាប់ផ្តើម ព្រោះគេបានបោះបង្គោលកំណត់រួច ហើយកាលពីចុង ខែសីហា ឆ្នាំ២០០៩។ លើសពីនេះមានលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ មួយចំនួនទៀត នឹងត្រូវរងប៉ះពាល់ដោយសារគំរោងសាងសង់ផ្លូវថ្មីនេះ នៅត្រង់ចំនុចបញ្ចប់របស់ផ្លូវថ្មី។

## ផលប៉ះពាល់ដោយប្រយោល:

ក្រៅពីអ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់ មានប្រជា-ពលរដ្ឋមួយចំនួនទៀត ដែលនឹងរងផលប៉ះពាល់ដោយប្រយោល ព្រោះពួកគាត់កំពុងរស់នៅតាមបណ្តោយផ្លូវជាតិលេខ ៧៨នេះ និងជា តំបន់ដែលមិនលិចទឹក ហើយដែលសព្វថ្ងៃពួកគាត់ប្រកបរបរទទួលទាន ដោយការលក់ដូរបន្តិចបន្តួចសំរាប់អ្នកធ្វើដំណើរឆ្លងកាត់ ប៉ុន្តែក្រោយ ពីផ្លូវវាងថ្មីនេះ ត្រូវបានស្ថាបនារួចរាល់ប្រាក់ចំណូលរបស់គាត់ដែល បានមកពីការលក់ដូរនឹងត្រូវធ្លាក់ចុះ ឬបាត់បង់តែម្តងពីព្រោះនឹង មិនមានការធ្វើចរាចរអ៊ឹូរអរដូចពេលមុនទៀត ដោយសារកំណាត់ផ្លូវ ត្រង់ចំនុចនេះត្រូវបានវាងទៅតំបន់ថ្មី។ សំនួរបានចោទថា តើអ្នកណា នឹងទទួលខុសត្រូវលើបញ្ហានេះ?

សព្វថ្ងៃនេះ ប្រជាពលរដ្ឋកំពុងមានការព្រួយបារម្ភចំពោះ ផលប៉ះពាល់ដែលនឹងកើតឡើងដោយសារគំរោងអភិវឌ្ឍន៍ទំនប់ វារីអគ្គិសនីសេសានក្រោមពីរនេះ ព្រោះពួកគាត់មិនទាន់ទទួលបាន ព័ត៌មានច្បាស់លាស់អំពីគំរោងនេះនៅឡើយ។ ចំពោះអង្គការសង្គម ស៊ីវិលវិញ ក៏មានការព្រួយបារម្ភផងដែរ ព្រោះគំរោងនេះមិនត្រឹម



សិស្សសាលានៅឃុំស្រែអង្រ្គងដែលត្រូវផ្លាស់ទៅទីតាំងលំនៅដ្ឋានថ្មី និងលំនៅដ្ឋានប្រជាពលរដ្ឋដែលត្រូវរុះរើ នៅត្រង់ចំនុចចុងបញ្ចប់ផ្លូវវាង

តែជាអាយុជីវិតរបស់មនុស្សទេ សូម្បីសត្វ និងរុក្ខជាតិ ក៏ប៉ះពាល់ ធ្ងន់ធ្ងរដែរ។ អង្គការសង្គមស៊ីវិល ក៏មានការបារម្ភផងដែរនៅពេល ដែលប្រជាពលរដ្ឋត្រូវគេបំលាស់ទីទៅកាន់ទីតាំងថ្មី ដែលស្ថិតនៅ តាមបណ្តោយផ្លូវថ្មីនេះ ពួកគាត់នឹងកាប់ទន្រ្ទានដីព្រៃ ដើម្បីធ្វើចំការ ផ្សេងៗ និងកាប់ឈើលក់ឱ្យឈ្មួញក្នុងស្រុកដើម្បីយកកំរៃដែលទង្វើ ទាំងនេះនឹងកាន់តែធ្វើឱ្យព្រៃឈើដែលកំពុងតែទទួលរងការកាប់ បំផ្លាញស្រាប់នេះ នឹងកាន់តែទទួលរងភាពរិចរិលថែមទៀត និង ធ្វើឱ្យបាត់បង់ជំរងសត្វព្រៃផងដែរ។



ទីតាំងប្រជាពលរដ្ឋលក់ដូរតាមផ្លូវ៧៨ ចាស់
ដែលនឹងត្រូវបាត់បង់អាជីវកម្មនៅពេលផ្លូវថ្មីត្រូវសាងសង់រួច

**សំណូមពរ**

ប្រជាពលរដ្ឋ ក៏ដូចជាក្រុមអង្គការសង្គមស៊ីវិលសំណូមពរឱ្យរាជរដ្ឋាភិបាល បន្ថែមការយកចិត្តទុកដាក់ជាងនេះទៀត លើការដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋដោយសារគំរោងអភិវឌ្ឍន៍នេះ។ ក្រុមអង្គការសង្គមស៊ីវិល សង្ឃឹមយ៉ាងមុតមាំថានឹងមានការសិក្សាអំពីផលប៉ះពាល់របស់គំរោងឱ្យបានលំអិតផ្សព្វផ្សាយអំពីគំរោងបានទូលំទូលាយ ព្រមទាំងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងការបញ្ចេញមតិយោបល់នៅក្នុងកិច្ចអភិវឌ្ឍន៍នេះ ពីព្រោះពួកគាត់ជាជនរងគ្រោះដោយផ្ទាល់។

*អត្ថបទ និងរូបភាពដោយៈ ក្រុមការងារបណ្តាញ*
*ប្រព្រឹត្តិកម្មតាំងទីលំនៅថ្មី RAN*

# ប្រជាពលរដ្ឋរងគ្រោះព្រោះតវ៉ារឿងទំនាស់ដីធ្លី

ប្រទេសកម្ពុជា មានផ្ទៃក្រឡា ១៨១,០៣៥គីឡូម៉ែត្រការ៉េ សំបូរសម្បត្តិធនធានធម្មជាតិច្រើនប្រភេទ និងដីមានជីជាតិដែលអំណោយផលដល់វិស័យឧស្សាហកម្ម និងកសិកម្ម។ លក្ខណៈសម្បត្តិដ៏ល្អទាំងនេះ បានទាក់ទាញអ្នកវិនិយោគទុនមកវិយោគនៅកម្ពុជាលើគ្រប់វិស័យ ជាពិសេសលើដំណាំកសិ-ឧស្សាហកម្ម និងដំណាំកសិកម្ម ជាហេតុធ្វើឱ្យប្រជាជនកម្ពុជាទទួលបានឱកាសការងារចំណេះដឹងបច្ចេកទេសទីផ្សារលក់ផលិតផលរបស់ខ្លួន និងចំណូលថវិកាជាតិដើម្បីអភិវឌ្ឍន៍ប្រទេស។ ទន្ទឹមនឹងការអភិវឌ្ឍន៍នេះ សម្បត្តិធនធានធម្មជាតិមួយចំនួន ដូចជាព្រៃឈើ សត្វព្រៃ មច្ឆាជាតិមួយចំនួនកំពុងទទួលរងផលប៉ះពាល់ឈានទៅរកការបាត់បង់ និងផលប៉ះពាល់បរិស្ថាន។ ជំលោះដីធ្លីកើតឡើងកាន់តែច្រើនគួរឱ្យព្រួយបារម្ភដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច សម្បទានព្រៃឈើដីធ្លីឡើងថ្លៃយ៉ាងខ្ពស់ ប្រព្រឹត្តដោយក្រុមឈ្មួញ ឬអ្នកមានអំណាចមួយចំនួន។ ជាមួយគ្នានេះដែរ ក៏មានអំពើពុករលួយ ការប្រើប្រាស់អំណាច បំពារបំពានច្បាប់ អំពើហិង្សាការបណ្តេញចេញដោយបង្ខំ និងការចាប់ឃុំខ្លួនប្រជាពលរដ្ឋ ដែលចេញមុខតវ៉ារឿងទំនាស់ដីធ្លីក៏កើតឡើងដែរ។ ទោះជាប្រទេសកម្ពុជាជួបនូវបញ្ហាដ៏ច្រើនយ៉ាងនេះក្តី បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងសកម្មទៅលើការអនុវត្តច្បាប់ និងបានដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្របន្ថែមទៀត។ ជាពិសេសថ្មីៗនេះ កម្ពុជា បានបង្កើតច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌក្រមព្រហ្មទណ្ឌ ច្បាប់អស្សាមិករណ៍ គោលនយោបាយដីធ្លី និងបង្កើតគណៈកម្មាធិការឯករាជ្យមួយត្រួតពិនិត្យមើលដំណើរការដោះស្រាយរឿងក្តីនៅតុលាការ។ ច្បាប់អំពើពុករលួយត្រូវបានរាជរដ្ឋាភិបាលកំពុងខិតខំជំរុញឱ្យចេញឆាប់នៅពេលខាងមុខនេះ ដោយគណៈរដ្ឋមន្ត្រីបានអនុម័តនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។ កិច្ចការទាំងនេះ គឺជាការចូលរួមចំណែកមួយយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងដោះស្រាយទំនាស់ប្រកបដោយយុត្តិធម៌ ដើម្បីកាត់បន្ថយជំលោះនាពេលអនាគត។

ជាក់ស្តែងដូចជាបញ្ហាទំនាស់ដីធ្លីមួយកន្លែងដែលមានទំហំ ៩២ ហិកតា នៅតំបន់ទំនប់ស្ទឹង ៧៨ ស្ថិតក្នុងភូមិត្រពាំងគ្រោះ

ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប រវាងប្រជាពលរដ្ឋ ១៧៥ គ្រួសារ រស់នៅភូមិចំនួន៦ក្នុង ឃុំជីក្រែង ស្រុកជីក្រែងជាមួយនឹងប្រជាពលរដ្ឋ ៤២ គ្រួសារទៀត ដែលមានស្ត្រីជាមេគ្រួសារ ៣០% រស់នៅភូមិត្រោះ ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ដែលបានកើតឡើងចាប់តាំងពីឆ្នាំ២០០៤-២០០៥ បន្តកើតមានរហូតដល់សព្វថ្ងៃនេះពុំទាន់ចប់នៅឡើយ។ ទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃនេះ បានបង្កឱ្យកើតមានអំពើហិង្សាជាច្រើនករណី ដូចជាការដុតកង់ឡាននៅមុខតុលាការខេត្តសៀមរាប ស្រែកដាក់បណ្តាសា ការចាក់សោរទ្វារបងតុលាការបង្ខាំងមន្ត្រីរាជការ ប្រជាពលរដ្ឋជាច្រើនទៀតរយៈពេលជិត ១ថ្ងៃ និងការប្រព្រឹត្តអំពើហិង្សាទៅលើប្រជាពលរដ្ឋ ខណៈពេលចុះអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ដោយបានបាញ់រះទៅលើក្រុមប្រជាពលរដ្ឋឃុំជីក្រែង បង្កឱ្យអ្នកភូមិ ៣នាក់រងរបួសធ្ងន់ធ្ងរ និងចាប់មនុស្ស (ប្រុស)ចំនួន ៤៣នាក់ដាក់ ខ្នោះយ៉ាងទារុណ និងការឃុំខ្លួនប្រជាពលរដ្ឋ ០៩ នាក់ នៅពន្ធនាគារខេត្តសៀមរាប។

ករណីនេះ ត្រូវបានក្រុមមន្ត្រីអង្គការសង្គមស៊ីវិលរួមសហការណ៍គ្នា ចុះអង្កេតអង្កេតដល់ទីកន្លែងកើតហេតុដោយបានចុះពិនិត្យទីតាំងដីទំនាស់ និង ធ្វើការសម្ភាសន៍ភាគីពាក់ព័ន្ធ រួមមានអ្នកភូមិទាំងពីរជាភាគីជំលោះ សាក្សី និង អាជ្ញាធរពាក់ព័ន្ធមួយចំនួន។ ជាលទ្ធផលបានបញ្ជាក់ឱ្យឃើញថា ដីទំនាស់នោះជាតំបន់វាលទំនាបបឹង និងដីព្រៃលិចទឹកតាមច្បាប់ត្រូវបានចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។ ក្នុងនោះភាគីទំនាស់ទាំងពីរក៏បានទទួលស្គាល់ដែរថា ពួកគាត់បានចូលទៅកាប់ឆ្ការរុករានកាន់កាប់នៅអំឡុងឆ្នាំ២០០៣-២០០៤ ដើម្បីបង្កបង្កើនផលស្រូវស្រែប្រាំង ដោយពុំមានអាជ្ញាធរណាទៅធ្វើការហាមឃាត់អ្វីឡើយ។ ក្រោយមកប្រជាពលរដ្ឋ បានដាក់ពាក្យស្នើសុំសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងសុំសង់អាងទឹកធ្វើស្រែប្រាំង ដើម្បីដោះស្រាយជីវភាពគ្រួសារ ប៉ុន្តែសំណើនេះ ត្រូវបានអាជ្ញាធរមូលដ្ឋានបដិសេធមិនទទួលស្គាល់ និងមានការពន្យល់ណែនាំមួយចំនួនដោយលើកពីកំហុសរបស់ប្រជាពលរដ្ឋជាច្រើនថាមិនបានចូលរួមគោរពច្បាប់។ នៅពេលទីផ្សារដីតំបន់នោះមានតំលៃឈ្នួញដីមួយចំនួនបានចូលទៅទិញ ជាហេតុនាំឱ្យបរិយាកាសទំនាស់ដីធ្លីនេះកាន់តែអាក្រក់ឡើងៗក្នុងនោះ ក៏មានអាជ្ញាធរមួយចំនួនទទួលបានផលប្រយោជន៍ដែរ ដោយយកប្រជាពលរដ្ឋម្ខាងទៀតធ្វើជាខែល។ នេះក៏ជាកត្តាមួយអូសបន្លាយពេលក្នុងការដោះស្រាយទំនាស់នៅក្រៅប្រព័ន្ធតុលាការ។ ចំពោះការសន្យារបស់អាជ្ញាធរខេត្តថានឹងផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រ ដែលជាយុទ្ធសាស្ត្រគន្លឹះមួយក្នុងការដោះស្រាយទំនាស់នេះក៏ពុំទាន់ឃើញមានចំណាត់ការអ្វីសោះនៅឡើយ ការសន្យានេះ វាប្រៀបដូចជាក្តីសុបិន្តល្អមួយតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ មានប្រជាពលរដ្ឋជាស្ត្រី មេគ្រួសារកំពុងប្រឈមមុខនឹងភាពក្រីក្រ ខ្វះខាតស្បៀងអាហារជំងឺផ្សេងៗ កូនៗរបស់គាត់បានបោះបង់ការសិក្សាហើយធ្វើចំណាកស្រុក ដើម្បីរកការងារធ្វើ។

ករណីនេះ មានតំណាងប្រជាពលរដ្ឋចំនួន៨នាក់ ជាបុរសត្រូវបានតុលាការខេត្តសៀមរាប ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ជាប់ចោទពីបទញុះញ៉ង់ឱ្យប្រព្រឹត្តអំពើហិង្សាក្នុងនោះជនត្រូវចោទ ចំនួន៣នាក់(ឈ្មោះ ស៊ិន សំឡី, ស៊ិន លាប និង ចាន់ លាប) ត្រូវបានចាប់ឃុំខ្លួន និង ដោះលែងឱ្យនៅក្រៅបណ្តោះអាសន្នវិញនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ បន្ទាប់ពីក្រុមប្រជាពលរដ្ឋ១៧៥គ្រួសារ ប្តឹងតវ៉ាធ្វើបាតុកម្មអស់រយៈពេលជាច្រើនថ្ងៃ និងការអន្តរាគមន៍ពីឯកឧត្តម ស៊ូ ភារិន្ទ អភិបាលខេត្តសៀមរាប។


ដីព្រៃលិចទឹកជាដីសាធារណៈរបស់រដ្ឋ


តំបន់ដីស្រែទំនាស់ ក្រោយពេលកាប់រាន

នៅថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៩ មានកងកំលាំងសមត្ថកិច្ចចំរុះ បានចុះអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់តុលាការខេត្តសៀមរាប បានកើតមានអំពើហិង្សាប្រព្រឹត្តដោយកំលាំងសមត្ថកិច្ចបាញ់រះ ទៅលើក្រុមប្រជាពលរដ្ឋ ១៧៥គ្រួសារ បណ្តាលឱ្យ៣នាក់រងរបួសធ្ងន់ធ្ងរ (របួសភ្លៅធ្លាយទាំងសង្ខាងម្នាក់ របួសសៀតថ្កាម្នាក់ និងម្នាក់ទៀតរបួសស្មាខាងឆ្វេង) និង ៤៣នាក់ត្រូវបានចាប់ដាក់ខ្នោះ ក្នុងនោះមាន ៩នាក់ត្រូវបានឃុំខ្លួននៅពន្ធនាគារ ខេត្តសៀមរាប។



ប្រជាពលរដ្ឋរងគ្រោះដោយការបាញ់រះ



ប្រជាពរដ្ឋដែលត្រូវបានគេចាប់ដាក់ខ្នោះខណៈពេលចុះអនុវត្តដីកា

**តើមានកត្តាអ្វីខ្លះជាប្រភពនាំឱ្យកើតមានទំនាស់ដីធ្លី និង អំពើហិង្សានេះឡើង?**

តាមរយៈការវិភាគបញ្ហាទំនាស់ និង ស្ថានភាពផ្លូវច្បាប់ ឃើញថាៈ

- **ភាពក្រីក្រៈ** កំណើនសមាជិកគ្រួសារ ការទទួលបានរបបដីពីរដ្ឋអំណាចមូលដ្ឋានតិចតួច និងការបោះបង់មុខរបរនេសាទដោយសារទិន្នផលត្រីថយចុះ ធ្វើឱ្យប្រជាពលរដ្ឋពុំមានប្រាក់ចំណូលគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារបានហើយក៏ងាកទៅចាប់ដីស្រែធ្វើស្រូវប្រាំង។ ករណីនេះវាប៉ះពាល់ទៅលើសិទ្ធិរស់រានមានជីវិត សិទ្ធិសេដ្ឋកិច្ច និង សង្គម ដែលរដ្ឋជាភាគីហត្ថលេខីលើសន្ធិសញ្ញាអន្តរជាតិទាំងឡាយត្រូវគោរព មានចែងក្នុងមាត្រា ៣ និង មាត្រា ២២ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស។ កម្ពុជា ក៏ជាប្រទេសហត្ថលេខីមួយដែរត្រូវគោរព ដូចមានចែងក្នុងមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។
- **តំលៃដីឡើងថ្លៃខ្ពស់ៈ** ខណៈពេលកម្ពុជាមានកំណើនសេដ្ឋកិច្ចជាតិ និងអភិវឌ្ឍន៍នោះទីផ្សារដី ក៏បានឡើងថ្លៃខ្លាំងដែរ ឈ្មួញជាច្រើនចុះទិញដី ដើម្បីលក់យកចំណេញ។ ប្រជាពលរដ្ឋបាននាំគ្នាចាប់ដីព្រៃលិចទឹក បឹងត្រពាំងសាធារណៈរបស់រដ្ឋកាប់រុករានបង្កបង្កើនផលស្រូវប្រាំងក្នុងគោលបំណងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន និងលក់។ ការកាន់កាប់ និង លក់ដីសាធារណៈរបស់រដ្ឋជាអំពើខុសច្បាប់ ដូចមានចែងក្នុងមាត្រា ១៥, ១៦, ១៨, ១៩, ៤៣ និង ត្រូវផ្តន្ទាទោសតាមមាត្រា ២៥៩ នៃច្បាប់ភូមិបាល។
- **ការមិនផ្តល់ឱកាសស្មើគ្នាៈ** អាជ្ញាធរមូលដ្ឋាន ក៏បានទទួលស្គាល់ដែរថា ដីតំបន់ទំនាស់នោះជាដីសាធារណៈរបស់រដ្ឋ ខណៈពេលប្រជាពលរដ្ឋ ១៧៥គ្រួសារ បានចូលទៅកាប់រាន (មុនប្រជាពលរដ្ឋ ៤២គ្រួសារ) និង ដាក់ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ អាជ្ញាធរបានបដិសេធដោយអះអាងថា វាជាដីបឹង ព្រៃលិចទឹក ព្រៃរនាមជាតំបន់ត្រីពង។ ប៉ុន្តែក្រោយមកដីតំបន់នោះ ត្រូវបានប្រជាពលរដ្ឋឃុំអន្លង់សំណ ចូលទៅកាន់កាប់ធ្វើស្រែប្រាំង និង សង់អាងទឹកស្រែប្រាំង អាជ្ញាធរមូលដ្ឋានបានទទួលស្គាល់ការកាន់កាប់នេះ។ អំពើនេះបំពានលើច្បាប់រដ្ឋធម្មនុញ្ញនៃពះរាជាណាចក្រកម្ពុជា មាត្រា៥០ ច្បាប់ភូមិបាលមាត្រា ១៦ និង ត្រូវផ្តន្ទាទោសមាត្រា ២៥៩។
- **ការអូសបន្លាយពេលក្នុងការផ្តល់ដីសម្បទានដីសង្គមកិច្ចៈ** អាជ្ញាធរមានសមត្ថកិច្ចបានសន្យាថា ផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រពិតប្រាកដ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ គេពុំទាន់ឃើញមានចំណាត់ការណាមួយនៅឡើយ។
- **ការអនុវត្តច្បាប់នៅមានកំរិតៈ** នៅពេលណាមានការប្តឹងតវ៉ារបស់ប្រជាពលរដ្ឋបញ្ហាដីធ្លី តំណាងប្រជាពលរដ្ឋតែងតែទទួលរងការគំរាមកំហែងចោទប្រកាន់ពីបទព្រហ្មទណ្ឌ និង ចាប់ឃុំខ្លួននៅក្នុងពន្ធនាគារ។

- **ការបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ៖** ក្រោយពីមានការចាប់ខ្លួនតំណាងប្រជាពលរដ្ឋ ៣នាក់ ជាប់ចោទពីបទញុះញង់ឱ្យប្រព្រឹត្តអំពើហឹង្សា។ អ្នកភូមិ ១៧៥គ្រួសារយល់ថាជារឿងអយុត្តិធម៌ ពុំមានភស្តុតាងត្រឹមត្រូវជាអំពើពុករលួយ និងជាការគំរាមកំហែងមួយបង្ខំឱ្យពួកគាត់ប្រគល់ដីឱ្យទៅភាគីម្ខាងទៀត និងក្រុមឈ្មួញ។
- **និទណ្ឌភាពលើមន្ត្រីប្រព្រឹត្តបទល្មើសក្នុងចុះអនុវត្តបទបញ្ជាអ្វីមួយ៖** ជាក់ស្តែងដូចជាក្នុងករណីនេះ កងកំលាំងសមត្ថកិច្ចដែលគេស្គាល់អត្តសញ្ញាណច្បាស់បានបាញ់រះទៅលើប្រជាពលរដ្ឋបណ្តាលឱ្យ ៣នាក់ រងរបួសយ៉ាងធ្ងន់ធ្ងរក្នុងលក្ខណៈមិនមែនជាកិច្ចការពារខ្លួន ឥឡូវនេះពុំទាន់មានការចោទប្រកាន់តុលាការនៅឡើយ បើទោះជាភាគីជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញា និងក្រុមអង្គការសង្គមស៊ីវិលខិតខំអន្តរាគមន៍យ៉ាងណាក៏ដោយ។ អំពើបាញ់រះនេះជាបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**អនុសាសន៍៖**

- អាជ្ញាធរមូលដ្ឋានគួរតែពន្យល់ និងហាមឃាត់ប្រជាពលរដ្ឋកុំឱ្យចូលទៅកាប់រានកាន់កាប់ដីសាធារណៈរបស់រដ្ឋ និងមានចំណាត់ការផ្លូវច្បាប់ស្មើៗគ្នា។ ចំណែកប្រជាពលរដ្ឋគួរតែទទួលស្គាល់ និងគោរពច្បាប់ទាំងអស់គ្នា ដោយបញ្ឈប់ការរុករានកាន់កាប់ដីសារធារណៈរបស់រដ្ឋ។
- គួរឱ្យមានការឯកភាពគ្នាដាក់ដីនោះជាតំបន់ស តាមដីកាសាលាខេត្ត ថ្ងៃទី១៦-៣-២០០៩។
- គួរតែមានការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសកាប់រុករានដីសាធារណៈរបស់រដ្ឋទៅតាមបញ្ញត្តិច្បាប់។
- អាជ្ញាធរមានសមត្ថកិច្ចដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ គួរតែដោះស្រាយទំនាស់នេះឱ្យបានឆាប់រហ័សដោយគោរពទៅតាមនីតិវិធី និងយុត្តិធម៌ ដើម្បីបញ្ចៀសអំពើហឹង្សា។
- ជនដែលបានប្រព្រឹត្តអំពើបាញ់រះទៅលើប្រជាពលរដ្ឋបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរនោះ ត្រូវតែបានចាប់ខ្លួនយកមកផ្តន្ទាទោសតាមច្បាប់។
- អាជ្ញាធរមានសមត្ថកិច្ចគួរតែចាត់វិធានការឱ្យបានឿនក្នុងការផ្តល់ដីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋ ដូចដែលខ្លួនសន្យា។
- រាជរដ្ឋាភិបាលគួរតែចាត់វិធានទប់ស្កាត់កុំឱ្យអាជ្ញាធរ ប្រើអំពើហិង្សាលើប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារបញ្ហាដីធ្លីទៀតនៅថ្ងៃអនាគត។

*រៀបរៀងដោយ៖ បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

# ផ្ទាំងរូបភាពស្តីពីសិទ្ធិភោគៈស្របច្បាប់

បុគ្គលទាំងឡាយណាដែលកាន់កាប់ដីឯកជនរបស់រដ្ឋដោយសន្តិវិធី និងគ្មានការជំទាស់ក្នុងរយៈពេលយ៉ាងតិច៥ឆ្នាំ មានសិទ្ធិស្របច្បាប់នៅលើដី និងមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ដើម្បីក្លាយជាកម្មសិទ្ធិករលើដីនេះបាន លុះត្រាតែបុគ្គលនោះកាន់កាប់ដីដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងសុចរិត ។ ការចាប់ផ្តើមចូលកាន់កាប់ត្រូវធ្វើឡើងនៅមុន ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ។



បានចូលកាន់កាប់ដីមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១



បានចូលកាន់កាប់ដោយសន្តិវិធី និងគ្មានការជំទាស់



បានរស់នៅដោយពិតប្រាកដ និងគ្មានអាក់ខាន



គ្មានហិង្សា ដឹងឮជាសាធារណៈ និងសុចរិត



បានកាន់កាប់ក្នុងរយៈពេលប្រាំឆ្នាំឡើង



សិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិ

USAID
ជំនួយពីពលរដ្ឋអាមេរិក

## ចំរៀង
## អាសូរធនធានធម្មជាតិ

១ ម្ដេចឃោរឃៅម្ល៉េះគ្មានក្ដីមេត្តា ឈ្លក់នឹងដុល្លារមោហាបាំងមុខ
លក់អស់ព្រៃឈើ ដីធ្លី សមុទ្រ គីរីបព័ទ្ធជាកេរ្ដិ៍កូនខ្មែរ ។
២ មើលចុះមន្ឆ្នាទាំងតូចទាំងធំ ស្រែកទ្រហោយំសុំក្ដីមេត្តា
មងអួនខ្សែរឆក់តាមផ្ដាច់សង្ខារ រស់រងទុក្ខខ្លោចផ្សាថ្ងៃណាផុតទុក្ខ ។
៣ ប្រជាទីក្រុង ស្រុកចំការ រងទុក្ខាព្រោះបាត់បង់ដី
រងទុក្ខគ្រឿងចក្រឈូសឆាយទាំងយប់ទាំងថ្ងៃ គេប្លន់យកដីគ្មានក្ដីមេត្តា ។
៤ អស់លោកអ្នកមានទ្រព្យធន សក្ដិយស គួរគិតស្រណោះឈាមខ្មែរដូចគ្នា
បើសិនរូបអ្នកតើឈឺចាប់ទេ ខ្មែរគ្រប់រូបារួមគ្នាដោះស្រាយ ។

**និពន្ធដោយ: លោក សេង សុខហេង**

**លំនាំបទ: វាលស្រែមួយរយ**

**សហគមន៍ខេត្តឧត្តរមានជ័យ និង ជាក្រុមការងារនៃបណ្ដាញកសាងសន្តិភាពសហគមន៍**

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

ការិយាល័យ : ផ្ទះលេខ ៩-១១, ផ្លូវ ៤៧៦ ទួលទំពូង ១
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារលេខ: ០២៣ ៩៩៤ ០៦៣
អ៊ីម៉ែល : ngoforum@ngoforum.org.kh
គេហទំព័រ : www.ngoforum.org.kh